# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)

# គម្រោងបញ្ចប់ផែនការ

# ខែមីនា ឆ្នាំ ២០១៤


I. **សេចក្តីផ្តើម** .......... 2

II. **វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស** .......... 5

III. **ផែនការបញ្ចប់ការស៊ើបអង្កេត** .......... 5

IV. **ផែនការបញ្ចប់សវនាការ** .......... 6

ក. សំណុំរឿង០០២/០១ .......... 7

ខ. សំណុំរឿង០០២/០២ .......... 7

ឃ. សំណុំរឿង០០៣ និង សំណុំរឿង០០៤ .......... 10

V. **ផែនការបញ្ចប់បណ្តឹងសាទុក្ខ** .......... 10

VI. **សេចក្តីសន្និដ្ឋាន** .......... 11


ឧបសម្ព័ន្ធ ៖ តារាងកំណត់ពេលវេលាតាមការគ្រោងទុកសម្រាប់ការបញ្ចប់ផែនការ ដែលរួមមានគ្រោងការសំខាន់ៗផង។

## I. សេចក្តីផ្តើម

1. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះវិសាមញ្ញ”) បានចាប់ផ្តើមដំណើរការរបស់ខ្លួននៅខែកុម្ភៈ ឆ្នាំ២០០៦ និងបានដំណើរការពេញលេញបន្ទាប់ពីការអនុម័តវិធានផ្ទៃក្នុងនៅក្នុងខែមិថុនា ឆ្នាំ២០០៧។ អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីកាត់សេចក្តី “មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩”[1]។ នៅក្នុងរបាយការណ៍មួយ ដែលបានដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិនៅខែមីនា ឆ្នាំ២០០៣ អគ្គលេខាធិការ ដំបូងឡើយបានបង្ហាញថា អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញ មានរយៈពេលបីឆ្នាំដើម្បីបញ្ចប់ការជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលទាំងអស់ “នៅពេលដែលការិយាល័យរបស់សហព្រះរាជអាជ្ញា បានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួន”[2]។ តារាងកំណត់ពេលវេលាត្រូវបានកែប្រែចាប់តាំងពីពេលនោះមក ហើយអគ្គលេខាធិការបានជូនដំណឹងជាផ្លូវការដល់មហាសន្និបាតអង្គការសហប្រជាជាតិនៅខែតុលា ឆ្នាំ២០១៣ថា តារាងកំណត់ពេលវេលារបស់អង្គជំនុំជម្រះវិសាមញ្ញ “មានគម្រោងសកម្មភាពតុលាការរហូតដល់ឆ្នាំ២០១៨ និងអាចបន្តហួសពីពេលវេលាកំណត់នេះទៅទៀត”[3]។

2. គម្រោងបញ្ចប់ផែនការនេះ បានបរិយាយយ៉ាងលម្អិតដោយ អ.វ.ត.ក. ក្នុងបរិបទនៃ សំណើដែលបច្ចុប្បន្ននៅចំពោះមុខសម័យប្រជុំលើកទី៦៩ដែលបានបន្តរបស់មហាសន្និបាត បន្ទាប់ពីអនុសាសន៍របស់គណៈកម្មាធិការទីប្រាំ ដែលក្នុងចំណោមបញ្ហាផ្សេងៗទៀត បានកំណត់អាណត្តិរបស់ អង្គជំនុំជម្រះវិសាមញ្ញ ឲ្យរៀបចំយុទ្ធសាស្ត្របញ្ចប់[4] ដោយមានផែនទីបង្ហាញផ្លូវច្បាស់លាស់មួយ។ ឯកសារនេះធ្វើឡើងដោយ អ.វ.ត.ក. ដោយមានការពិគ្រោះយោបល់តាមរយៈការិយាល័យរដ្ឋបាល ជាមួយចៅក្រមអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាអំពីការទទួលខុសត្រូវរបស់ពួកគេ។ អ.វ.ត.ក. គិតទុកជាមុនថានៅពេលខាងមុខខ្លួននឹងធ្វើបច្ចុប្បន្នភាពផែនការបញ្ចប់នេះរៀងរាល់ត្រីមាស។

3. ឯកសារនេះផ្តោតជាពិសេសលើការវិវត្តន៍នាពេលថ្មីៗនេះ នៅក្នុងសំណុំរឿងទាំងបីដែលកំពុងរង់ចាំនៅចំពោះមុខ អ.វ.ត.ក. និងផ្តល់នូវព័ត៌មានអំពីប្រភេទនៃរឿងក្តី ព្រមទាំងស្ថានភាពនៃសំណុំរឿងទាំងនោះព្រមទាំងជំហាននានាដែលត្រូវបំពេញ មុនពេលកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការទាក់ទិននឹងសំណុំរឿងកំពុងរង់ចាំបច្ចុប្បន្ននៅចំពោះមុខ អ.វ.ត.ក. អាចនឹងបញ្ចប់ជាស្ថាពរតាមផ្លូវច្បាប់។

4. អង្គជំនុំជម្រះវិសាមញ្ញ បានបញ្ចប់ជាស្ថាពរនូវកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០១ ប្រឆាំងនឹង កាំង ហ្គេកអ៊ាវ ហៅឌុច នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូលបានចេញសាលដីការបស់ខ្លួនលើបណ្តឹងសាទុក្ខកាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២។ កាំង ហ្គេកអ៊ាវ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ

---

[1] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

[2] របាយការណ៍របស់អគ្គលេខាធិការស្តីពីការជំនុំជម្រះខ្មែរក្រហម ឯកសារ A/57/769 កថាខណ្ឌ៥៦។

[3] សំណើសុំថវិកាជំនួយផ្តល់ឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឯកសារ A/68/532 កថាខណ្ឌ៣៨។

[4] គណៈកម្មាធិការណែនាំលើបញ្ហាថវិកា និងរដ្ឋបាល ទាក់ទងនឹងសំណើដដែល ក៏បានផ្តល់អនុសាសន៍ផងដែរថា “ផែនការថវិកាហួសពីរយៈពេលឆ្នាំ២០១៤-២០១៥ ត្រូវបានបង្កើតឡើង ផ្អែកលើការព្យាករណ៍ដ៏ម៉ត់ចត់នៃបន្ទុកការងារ ដែលទាក់ទងនឹងការបញ្ចប់ទាន់ពេលវេលានៃសំណុំរឿងបីដែលនៅសល់ និង ការបង្កើត និងការអនុវត្តវិធីសាស្ត្រគ្រប់គ្រងសំណុំរឿងដ៏ច្បាស់លាស់មួយ...”។ សូមមើលរបាយការណ៍លើកទី១៣ របស់គណៈកម្មាធិការណែនាំលើបញ្ហាថវិការ និងរដ្ឋបាល ស្តីពីថវិកាកម្មវិធីដែលបានស្នើឡើងសម្រាប់ពីរឆ្នាំម្តង ២០១៤-២០១៥ ឯកសារ A/68/7/Add.12 កថាខណ្ឌ ៣២(ង)។

អស់មួយជីវិត និងត្រូវបានបញ្ជូនទៅពន្ធនាគារខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ដើម្បីអនុវត្តទោសដែលនៅសល់ ។

5. បច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង០០២ ដែលជាការជំនុំជម្រះរួមលើ ខៀវ សំផន និង នួន ជា។ ជនជាប់ចោទទីបី ឈ្មោះ អៀង សារី បានទទួលមរណភាពកាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ហើយកិច្ចដំណើរការនីតិវិធីលើរូបគាត់ ត្រូវបានបញ្ចប់នៅថ្ងៃនោះផងដែរ។ ជនជាប់ចោទទីបួន ឈ្មោះ អៀង ធីរិទ្ធ ត្រូវបានរកឃើញថាមិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមនៅក្នុងសវនាការ ដោយសារតែស្ថានភាពជំងឺវង្វេងស្មារតីកាន់តែធ្ងន់ធ្ងរ ហើយកិច្ចនីតិវិធីលើរូបគាត់បច្ចុប្បន្ននេះត្រូវបានព្យួរតាមរយៈការផ្អាកកិច្ចនីតិវិធីជាផ្លូវការ។ បច្ចុប្បន្នគាត់ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ។ គាត់មិនត្រូវបានអនុញ្ញាតឲ្យចាកចេញពីប្រទេសកម្ពុជា ដោយគ្មានការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង គាត់មិនអាចផ្លាស់ប្តូរអាសយដ្ឋានស្នាក់នៅដោយមិនជូនដំណឹងជាមុននោះទេ ហើយអាណាព្យាបាលស្របច្បាប់របស់គាត់ ត្រូវផ្តល់របាយការណ៍ប្រចាំខែដើម្បីបញ្ជាក់អំពីការអនុវត្តលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការ។ អៀង ធីរិទ្ធ ក៏ត្រូវទទួលបានការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រពីរដងក្នុងមួយឆ្នាំ ដើម្បីវាយតម្លៃថាតើមានការប្រែប្រួលណាមួយទៅលើសមត្ថភាពបញ្ញាស្មារតី ដែលអាចប៉ះពាល់ដល់សម្បទារបស់គាត់ក្នុងការចូលរួមសវនាការផងដែរ។

6. អង្គជំនុំជម្រះបានបំបែកបទចោទនៅក្នុងសំណុំរឿង០០២ ទៅជាសវនាការតូចៗចំនួនពីរ ឬច្រើនបន្តទៀត។ ការបង្ហាញភ័ស្តុតាងនៅក្នុងសវនាការដំណាក់កាលទីមួយ ដែល អ.វ.ត.ក. កំណត់ឈ្មោះសំណុំរឿងថា សំណុំរឿង០០២/០១ ត្រូវបានបញ្ចប់នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ និងសេចក្តីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោល បានបញ្ចប់កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣។ អង្គជំនុំជម្រះនឹងចេញសាលក្រមនៃការជំនុំជម្រះនេះ នៅត្រីមាសទីពីរ ឆ្នាំ២០១៤។ ទន្ទឹមពេលនៃដំណើរការព្រាងសាលក្រមនេះដែរ អង្គជំនុំជម្រះសាលាដំបូង ក៏រៀបចំការកិច្ចនីតិវិធីទាក់ទិននឹងការជំនុំជម្រះបន្ទាប់ទៀត គឺសំណុំរឿង០០២/០២ ដែលនឹងត្រូវផ្តោតលើការចោទប្រកាន់មួយចំនួន ឬទាំងអស់ទៅលើជនជាប់ចោទសេសសល់ពីររូបទៀត។ សវនាការបឋមនៃការជំនុំជម្រះមួយនៅក្នុងសវនាការទីពីរ គ្រោងនឹងចាប់ផ្តើមនៅត្រីមាសទីបី ឆ្នាំ២០១៤ អាស្រ័យទៅលើការវិវត្តនៃការរៀបចំកិច្ចដំណើរការនីតិវិធីដែលនៅសល់។ សវនាការលើភ័ស្តុតាងរំពឹងថានឹងចាប់ផ្តើមនៅត្រីមាសចុងក្រោយនៃឆ្នាំ២០១៤។

7. សំណុំរឿង០០៣ និង ០០៤ បច្ចុប្បន្ននេះ កំពុងស្ថិតនៅក្នុងដំណាក់កាលស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កំពុងស៊ើបអង្កេតសំណុំរឿងទាំងពីរនេះយ៉ាងសកម្ម ដែលពាក់ព័ន្ធនឹងការចោទប្រកាន់លើជនសង្ស័យមិនកំណត់ឈ្មោះចំនួនប្រាំរូប[5]។ គ្មានជនសង្ស័យណាម្នាក់ត្រូវបានចាប់ខ្លួន ឬចោទប្រកាន់ជាផ្លូវការនោះទេ ហើយអត្តសញ្ញាណរបស់ពួកគេនៅតែរក្សាជាសម្ងាត់។ ការស៊ើបអង្កេតក្នុងសំណុំរឿងទាំងនេះត្រូវបានរំពឹងថា នឹងបញ្ចប់នៅត្រីមាសទីពីរ ឆ្នាំ២០១៤ ហើយសេចក្តីសម្រេចណាមួយក្នុងទម្រង់ជាដីកាដំណោះស្រាយ លើបញ្ហាចោទថាតើជនសង្ស័យណាមួយ(ច្រើន) អាចនឹងត្រូវចោទប្រកាន់និងបញ្ជូនខ្លួនទៅជំនុំជម្រះនោះ រំពឹងថានឹងធ្វើឡើងនៅត្រីមាសទីបួន ឆ្នាំ២០១៤។

8. សហព្រះរាជអាជ្ញាបានលើកឡើងជាសាធារណៈថា បន្ទាប់ពីសំណុំរឿង០០៣ និង០០៤ នឹងលែងមានសំណុំរឿងបន្ថែមទៀតហើយ[6]។ ចំនួនសំណុំរឿងដែលមានបច្ចុប្បន្ន គឺជាចំនួនសំណុំរឿងសរុបដែលនឹងត្រូវដោះស្រាយដោយ អ.វ.ត.ក.។

---

[5] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៩ (www.eccc.gov.kh/sites/default/files/media/ECCC_Act_Int_Co_Prosecutor_8_Sep_2009_(Eng).pdf)។

[6] សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី - ការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីចំនួនពីរ ថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ២០០៩ (www.eccc.gov.kh/sites/default/files/media/ECCC_Act_Int Co Prosecutor 8 Sep_2009_(Eng).pdf)

9. គម្រោងបញ្ចប់ផែនការរបស់អង្គជំនុំជម្រះវិសាមញ្ញ មានគ្រោងការសំខាន់ចំនួន១៧សម្រាប់សំណុំរឿងចំនួនបីដែលនៅសេសសល់។ គ្រោងការសំខាន់ដែលនៅសេសសល់នៅក្នុងសំណុំរឿង០០២[7] និងការព្យាករណ៍ ដែលពាក់ព័ន្ធគឺ៖

(i) ការចេញសាលក្រមនៅក្នុងសំណុំរឿង០០២/០១ (ត្រីមាសទីពីរ ឆ្នាំ២០១៤)

(ii) ពេលវេលាកំណត់នៃការដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម នៅក្នុងសំណុំរឿង០០២/០១ (ត្រីមាសទីបី ឆ្នាំ២០១៤)

(iii) ការចេញសាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ ប្រសិនបើមាន(ត្រីមាសទីមួយ ឆ្នាំ២០១៦)

(iv) ការចេញសេចក្តីសម្រេចលើវិសាលភាពនៃសំណុំរឿង ០០២/០២ (ខែមេសា ឆ្នាំ២០១៤)

(v) ការបើកសវនាការបឋមក្នុងសំណុំរឿង ០០២/០២ (ត្រីមាសទី៣ ឆ្នាំ២០១៤)

(vi) ការចាប់ផ្តើមសវនាការលើអង្គសេចក្តី/ភ័ស្តុតាង ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទីបួន ឆ្នាំ២០១៤)

(vii) ការបញ្ចប់សវនាការលើអង្គសេចក្តី/ភ័ស្តុតាង ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទីបី ឆ្នាំ២០១៦)

(viii) សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទីបួន ឆ្នាំ២០១៦)

(ix) ការចេញសាលក្រមនៅក្នុងសំណុំរឿង០០២/០២ (ត្រីមាសទីបី ឆ្នាំ២០១៧)

(x) ពេលវេលាកំណត់នៃការដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទីបួន ឆ្នាំ២០១៧) និង

(xi) ការចេញសាលដីកាលើបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង០០២/០២ ប្រសិនបើមានបណ្តឹងសាទុក្ខ (ត្រីមាសទីពីរ ឆ្នាំ២០១៩)។

10. នៅក្នុងសំណុំរឿង ០០៣ និង ០០៤ គ្រោងការដាច់ដោយឡែក ត្រូវបានកំណត់សម្រាប់ដំណាក់កាលស៊ើបអង្កេត ដែលនៅសេសសល់ ហើយក្នុងករណីមានការចោទប្រកាន់នោះ នឹងមានគ្រោងការបន្ថែមទៀតសម្រាប់ដំណាក់កាលជំនុំជម្រះ និងបណ្តឹងសាទុក្ខ[8]។ គ្រោងការសំខាន់សម្រាប់ដំណាក់កាលស៊ើបអង្កេតដែលនៅសេសសល់គឺ៖

---

។ និង សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាទាក់ទិននឹងការស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣ ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១២ (www.eccc.gov.kh/sites/default/files/media/ECCC%20OCP%205%20June%202012%20En.pdf) និងសេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងចំនួនរឿងក្តីរបស់ អ.វ.ត.ក. ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ (http://www.eccc.gov.kh/en/articles/statement-international-co-prosecutor-regarding-eccc-caseload)។

[7] នៅក្នុងករណីដែលសំណុំរឿង០០២ ត្រូវបានបំបែកបន្ថែមទៀតតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទៅលើវិសាលភាពនៃសំណុំរឿង០០២/០២ ដែលរំពឹងថានឹងចេញនៅខែមេសា ឆ្នាំ២០១៤ វានឹងតម្រូវឲ្យមានសំណុំរឿង០០២/០៣។

[8] ដូចដែលកត់សម្គាល់ត្រង់កថាខណ្ឌទី២៨ខាងក្រោម ដោយសាស្ថានភាពនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន នៅពេលនេះយើងមិនអាចព្យាករណ៍នូវចំណុចពេលវេលាជាក់លាក់ទាក់ទិននឹងគ្រោងការជំនុំជម្រះក្តីបានឡើយ។ នៅក្នុងករណីដែលរឿងក្តីនេះត្រូវបញ្ជូនទៅជំនុំ

(xii) ការជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ (ត្រីមាសទីពីរ ឆ្នាំ២០១៤)

(xiii) ការចេញដីកាដំណោះស្រាយ ជាមួយនឹងសេចក្តីសម្រេចថាតើបញ្ជូនរឿងទៅជម្រះឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទីបួន ឆ្នាំ២០១៤) និង

(xiv) សេចក្តីសម្រេចដោយអង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយ ទោះបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចដំណើរការនីតិវិធីតុលាការក្នុងរឿងក្តីទាំងនេះ (ត្រីមាសទីពីរ ឆ្នាំ២០១៥)។

## II. វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស

11. ដំណើរការប្រកបដោយប្រសិទ្ធភាពរបស់អង្គជំនុំជម្រះវិសាមញ្ញ កន្លងទៅត្រូវបានរំខានដោយអសន្តិសុខផ្នែកហិរញ្ញវត្ថុដែលចេះតែបន្តកើតមាន ដែលបណ្តាលឲ្យបុគ្គលិកជាតិបានធ្វើកូដកម្មមិនចូលធ្វើការចំនួនពីរលើកក្នុងអំឡុងឆ្នាំ២០១៣ ព្រមទាំងបុគ្គលិកចេញចូលពីមុខតំណែងដោយមិនសមហេតុផល។ អនុសាសន៍របស់មហាសន្និបាតទៅលើឧបត្ថម្ភធនចំនួន ១៥,៥ លានដុល្លារសម្រាប់ភាគីអន្តរជាតិ នៃ អ.វ.ត.ក. គឺជាវិធានការដ៏សំខាន់ដែលបានធ្វើឲ្យមានស្ថិរភាពដល់ស្ថានភាពថវិកាសម្រាប់ឆ្នាំ២០១៤។ ការអភិវឌ្ឍជាវិជ្ជមានមួយទៀតគឺការបង្កើនវិភាគទានពីរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការធ្វើការកៀរគរថវិកា។ជាការសំខាន់គឺត្រូវមានការកៀរគរថវិកាបន្ថែមដើម្បីធ្វើឲ្យមានស្ថិរភាពដល់ភាគីជាតិនៃ អ.វ.ត.ក.។

12. ការប៉ាន់ស្មានលើតារាងកំណត់ពេលវេលាខាងក្រោម ត្រូវបានធ្វើឡើងដោយផ្អែកមូលដ្ឋានថាកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការ នឹងមិនត្រូវរំខានបន្ថែមទៀតដោយសារតែអសន្តិសុខផ្នែកហិរញ្ញវត្ថុ។ ប្រសិនបើអសន្តិសុខផ្នែកហិរញ្ញវត្ថុនៅតែបន្ត យើងនឹងចាំបាច់ត្រូវកែសម្រួលតារាងពេលវេលាឡើងវិញ។

## III. ផែនការបញ្ចប់ការស៊ើបអង្កេត

13. តារាងកំណត់ពេលវេលានៃការបញ្ចប់ការស៊ើបអង្កេត ត្រូវបានកំណត់ដោយកត្តានានាដូចជា៖ ប្រភេទ និងភាពស្មុគស្មាញនៃរឿងក្តី ចំនួនសាក្សីដែលត្រូវស្តាប់សក្ខីកម្ម ចំនួនបេសកម្មចុះដល់ទីកន្លែងដែលតម្រូវឲ្យមាន បុគ្គលិកមានគុណវុឌ្ឍិ ការបង្អាក់ជាក់ស្តែងក្នុងការបំពេញកិច្ចស៊ើបសួរ ចំនួនញត្តិដែលដាក់ដោយភាគីនានា ថិរវេលាដែលតម្រូវដោយអង្គបុរេជំនុំជម្រះដើម្បីចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំរបស់ភាគីនានា និងការពិចារណាពាក់ព័ន្ធនានា។ ដោយមានកត្តាប្រែប្រួលទាំងនេះ ការស្មានទុកជាមុននូវតារាងកំណត់ពេលវេលាអនុវត្តគ្រោងការ អាចផ្អែកលើបទពិសោធន៍កន្លងទៅទាំងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងក្នុងស្ថាប័នតុលាការប្រហាក់ប្រហែលគ្នានេះ។

14. វាមានលក្ខណៈសំខាន់ក្នុងការរំឭកដោយសង្ខេបអំពីដំណាក់កាលនីតិវិធីផ្សេងៗ ដែលសហចៅក្រមស៊ើបអង្កេតត្រូវអនុវត្តតាម ដើម្បីបំពេញឲ្យបានពេញលេញនូវដំណើរការស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតត្រូវស៊ើបអង្កេតអង្គហេតុនានាដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដែលដាក់ដោយសហព្រះរាជអាជ្ញា។ នៅពេលបំពេញកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចនឹងបំពេញកិច្ចស៊ើបសួរ ដែលនាំឲ្យបញ្ជាក់នូវការពិត។ នៅគ្រប់ករណីទាំងអស់ ពួកគេត្រូវបំពេញកិច្ចស៊ើបសួរដោយអនាគតិ។ ភាគីនានាអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរជាក់លាក់មួយចំនួន។ ការបដិសេធមិនពិចារណាលើសំណើសុំអាចនឹងត្រូវបានប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។

---

ជម្រះ គ្រោងការនៃសវនាការលើអង្គសេចក្តីគឺអាចដូចទៅនឹងប្រការដែលមានចែងនៅក្នុងកថាខណ្ឌទី៩(v) តាមរយៈ(xi) ខាងលើទាក់ទិននឹងសំណុំរឿង០០២/០២។

15. នៅពេលសហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា ការស៊ើបអង្កេតត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងដល់ភាគីទាំងអស់។ ភាគីមានរយៈពេល១៥ថ្ងៃដើម្បីស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម លើកលែងតែភាគីបោះបង់រយៈពេលនោះចោល។ ប្រសិនបើសហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធចោលសំណើបែបនេះ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាសម្រេចមួយដែលមានសំអាងហេតុ។ នៅក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីការជូនដំណឹងអំពីដីកាសម្រេចនេះ ភាគីទាំងអស់អាចដាក់បណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ នៅពេលដែលរយៈពេលនេះ បានផុតកំណត់, ត្រូវបានបោះបង់ចោល ឬបណ្តឹងឧទ្ធរណ៍ដែលបានលើកឡើងខាងលើត្រូវបានជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនសំណុំរឿងភ្លាមៗទៅឱ្យសហព្រះរាជអាជ្ញា ដើម្បីចេញដីកាសន្និដ្ឋានស្ថាពរ។ សហព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ និងបង្វិលសំណុំរឿងឱ្យសហចៅក្រមស៊ើបអង្កេត នៅក្នុងរយៈពេល៤៥ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវបានឃុំខ្លួន និងរយៈពេល៣ខែនៅក្នុងរឿងក្តីផ្សេងទៀត។ លើកលែងតែក្រោយពេលដំណាក់កាលដែលលើកឡើងខាងលើនេះត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេតនឹងចេញដីកាដំណោះស្រាយថាតើត្រូវចោទប្រកាន់ជនត្រូវចោទ ដែលត្រូវបញ្ជូនរូបគាត់ទៅជំនុំជម្រះ ឬត្រូវទម្លាក់ចោលការចោទប្រកាន់។ សហព្រះរាជអាជ្ញាអាចនឹងដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទៅអង្គបុរេជំនុំជម្រះ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់បណ្តឹងឧទ្ធរណ៍ តែក្នុងករណីដីកាដំណោះស្រាយបដិសេធចោលការចោទប្រកាន់ និងក្នុងករណីដែលសហព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធចោលការចោទប្រកាន់នេះ។ បន្ថែមពីលើនេះ អង្គបុរេជំនុំជម្រះបានផ្តល់នូវសិទ្ធិឱ្យជនត្រូវចោទជំទាស់នឹងធាតុផ្សំយុត្តាធិការនៅក្នុងដីកាដំណោះស្រាយតាមរយៈបណ្តឹងឧទ្ធរណ៍។ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ត្រូវតែដាក់នៅក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីដីកាសម្រេចនេះ។ អង្គបុរេជំនុំជម្រះអាចនឹងកែប្រែ ឬតម្កល់ដីកាដំណោះស្រាយនេះ។

16. កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ បានចាប់ផ្តើមដំណើរការក្រោយពីការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាអន្តរជាតិនៅខែកញ្ញាឆ្នាំ២០០៩។ ដោយអនុលោមតាមវិធានផ្ទៃក្នុងនៃ អ.វ.ត.ក. សហចៅក្រមស៊ើបអង្កេត បានធ្វើកំណត់ហេតុនៃការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរក្នុងសំណុំរឿងទាំងនេះ។ ហេតុដូចនេះ សហចៅក្រមស៊ើបអង្កេតទាំងពីររូបកំពុងតែជ្រើសរើសវិធីសាស្ត្ររៀងៗខ្លួននៅក្នុងសំណុំរឿងទាំងនេះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិកំពុងតែស៊ើបអង្កេតយ៉ាងសកម្មលើការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ នៅមូលដ្ឋានបទល្មើសចំនួនជាង១០ផ្សេងៗពីគ្នាក្នុងសំណុំរឿង០០៣ និង មូលដ្ឋានបទល្មើសចំនួន៥៥ក្នុងសំណុំរឿង ០០៤។ ចាប់តាំងពីសហចៅក្រមអន្តរជាតិបច្ចុប្បន្ន ចាប់ផ្តើមបំពេញភារកិច្ចនៅខែតុលា ឆ្នាំ២០១២ មក មានការបំពេញបេសកកម្មដល់ទីកន្លែងកើតហេតុ ចំនួនជាង៥០លើក និង ធ្វើកិច្ចសម្ភាសន៍សាក្សី បានចំនួនជាង១៧០លើក។ ពេលវេលាស្មានទុកដ៏សុក្រឹតដែល អាចផ្តល់ជូនបាននៅខណៈនេះ គឺ៖ (i) កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ នឹងត្រូវបញ្ចប់ ត្រឹមចុងត្រីមាសទីពីរ ឆ្នាំ២០១៤ (ii) ដីកាដំណោះស្រាយ នឹងត្រូវចេញនៅចុងត្រីមាសទីបួន ឆ្នាំ២០១៤ និង (iii) រាល់បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយនឹងត្រូវសម្រេចសេចក្តីដោយ អង្គបុរេជំនុំជម្រះនៅចុងត្រីមាសទីពីរ ឆ្នាំ២០១៥។

## IV. ផែនការបញ្ចប់សវនាការ

17. តារាងពេលវេលានៃការបញ្ចប់សវនាការត្រូវកំណត់ដោយកត្តានានាដូចជា៖ លក្ខណៈ និងភាពស្មុគស្មាញនៃសំណុំរឿង បញ្ហាសុខភាពរបស់ជនជាប់ចោទដែលមានវ័យចាស់ជរា ចំនួនសាក្សីដែលត្រូវកោះហៅ និងរយៈពេលនៃការធ្វើសក្ខីកម្មរបស់សាក្សីទាំងនោះ ការបង្អាក់ជាក់ស្តែងនានាក្នុងការបំពេញកិច្ចដំណើរការនីតិវិធី ចំនួនញត្តិដាក់ដោយភាគី និងការពិនិត្យពិច័យផ្នែករដ្ឋបាលផ្សេងៗទៀត។ ដោយមានកត្តាប្រែប្រួលទាំងនេះ ការស្មានទុកជាមុននូវតារាងកំណត់ពេលវេលាអនុវត្តគ្រោង

ការគឺផ្អែកលើបទពិសោធន៍កន្លងទៅ ទាំងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងស្ថាប័នតុលាការប្រហាក់ប្រហែលគ្នានេះ។

18. ការប្រជុំរៀបចំសវនាការចំនួនមួយ ឬច្រើន តែងតែបានរៀបចំឡើងមុនពេលការចាប់ផ្តើមសវនាការជាក់ស្តែង។ ការជំនុំជម្រះ ចាប់ផ្តើមដោយសវនាការបឋម។ នៅក្នុងសវនាការបឋមនេះ អង្គជំនុំជម្រះសាលាដំបូងត្រូវពិចារណាទៅលើបញ្ជីសាក្សីសក្ខីពល និងអ្នកជំនាញ ដែលដាក់ជូនដោយភាគីព្រមទាំងអញ្ញត្រកម្ម លើកឡើងដោយភាគី ហើយភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តួចផ្តើមនូវចំណុចជាក់លាក់អំពីសំណងដែលខ្លួនស្នើសុំ។ សវនាការលើអង្គសេចក្តីនឹងចាប់ផ្តើមដោយមានការធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបពីសំណាក់សហព្រះរាជអាជ្ញា ហើយជនជាប់ចោទអាចធ្វើការឆ្លើយតបដោយសង្ខេបបាន មុនពេលអង្គជំនុំជម្រះសាលាដំបូង ចាប់ផ្តើមតាំងសំណួរដល់ជនជាប់ចោទ ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី និងស្តាប់នូវការបង្ហាញភ័ស្តុតាង។ សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ដើម្បីផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿ ដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។ ក្រោយពេលពិនិត្យភ័ស្តុតាងទាំងអស់រួចហើយ អង្គជំនុំជម្រះនឹងស្តាប់នូវការបិទកិច្ចពិភាក្សាដេញដោលពីសំណាក់ភាគី មុនពេលពិភាក្សាគ្នាជាសម្ងាត់ដើម្បីសម្រេចសេចក្តី។ ប្រសិនបើជនជាប់ចោទត្រូវផ្តន្ទាទោស អង្គជំនុំជម្រះនឹងសម្រេចទៅលើទោសដែលបានកំណត់នៅក្នុងសាលក្រមរបស់ខ្លួន។ ដោយឈរលើមូលដ្ឋាននៃជំហាននីតិវិធីទាំងនេះទើបយើងកំណត់បាននូវគ្រោងការសំខាន់ៗផ្សេងៗគ្នាសម្រាប់សវនាការនីមួយៗបាន។

## ក. <u>សំណុំរឿង០០២/០១</u>

19. សវនាការបឋមក្នុងសំណុំរឿង០០២ ប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៧ រហូតដល់ថ្ងៃ៣០ ខែមិថុនា ឆ្នាំ២០១១។ ក្នុងខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបំបែកនូវបទចោទក្នុងសំណុំរឿង០០២ទៅជាសវនាការចំនួនពីរឬច្រើន អនុលោមទៅតាមវិធានផ្ទៃក្នុង ដែលនឹងត្រូវវិនិច្ឆ័យដោយអង្គជំនុំជម្រះទៅតាមលំដាប់លំដោយតាមការយល់ឃើញថាសមស្រប។ បទចោទនៅក្នុងការជំនុំជម្រះដំបូង (ក្នុងសំណុំរឿង០០២/០១) ផ្តោតសំខាន់ទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទិននឹងការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ និងទីប្រជុំជន ព្រមទាំង ការសម្លាប់ទាហាន លន់ នល់ នៅទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ ភ្លាមៗក្រោយពេលខ្មែរក្រហមឡើងកាន់អំណាច ក្នុងខែមេសា ឆ្នាំ១៩៧៥។ អង្គជំនុំជម្រះក៏បានស្តាប់នូវការបង្ហាញភ័ស្តុតាងទាក់ទិននឹងប្រវត្តិបក្សកុម្មុយនិស្តកម្ពុជា រចនាសម្ព័ន្ធចាត់តាំងនៃកម្ពុជាប្រជាធិបតេយ្យ និងតួនាទីរបស់ជនជាប់ចោទពាក់ព័ន្ធនឹងគោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យពាក់ព័ន្ធនឹងបទចោទទាំងអស់ក្នុងសំណុំរឿង០០២។

20. សវនាការលើអង្គសេចក្តីចាប់ផ្តើមដោយមានការធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១។ សាក្សីចំនួន៥៨រូប ភាគីដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣១រូប និងអ្នកជំនាញចំនួន ៣រូប បានផ្តល់សក្ខីកម្មនៅអំឡុងពេលសវនាការ ហើយការបិទកិច្ចពិភាក្សាដេញដោលប្រព្រឹត្តទៅនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣។ ដូច្នេះ ដំណើរការនីតិវិធីសវនាការទាំងមូលប្រព្រឹត្តទៅអស់រយៈពេល ២២២ថ្ងៃ ។ បច្ចុប្បន្ននេះអង្គជំនុំជម្រះសាលាដំបូងកំពុងធ្វើការផ្តោះទៅរកការ ចេញសាលក្រមលើអង្គសេចក្តីនៅត្រីមាសទីពីរ ឆ្នាំ២០១៤។

## ខ. <u>សំណុំរឿង០០២/០២</u>

21. នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងសាទុក្ខ ជំទាស់ទៅនឹងការបំបែកសំណុំរឿងរបស់អង្គ ជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ថា សវនាការលើភ័ស្តុតាងនៅក្នុងសំណុំរឿងទីពី(០០២) សំណុំរឿង០០២/០២ គួរតែចាប់ផ្តើមកាន់តែឆាប់កាន់តែប្រសើរក្រោយ ពីការបិទកិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង០០២/០១។ អង្គជំនុំជម្រះ តុលាការ

កំពូល ក៏បានសម្រេចថាវិសាលភាពនៃសំណុំរឿង០០២/០២ ជាតំណាងឲ្យដីកាបញ្ជូនទៅជំនុំជម្រះ ដូច្នេះ តុលាការកំពូលបង្គាប់ថាអង្គជំនុំជម្រះជាអបប្បរមាគួរតែបញ្ចូលបទចោទដែលពាក់ព័ន្ធឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មន្ទីរសន្តិសុខ ស២១ នៅភ្នំពេញ សហករណ៍ចំនួនមួយ និងការដ្ឋានចំនួនមួយ[9]។

22. អង្គជំនុំជម្រះសាលាដំបូងបានបើកកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី១១ និងទី១២ ខែធ្នូ ឆ្នាំ២០១៣ ដើម្បីត្រៀមលក្ខណៈសម្រាប់សវនាការបន្ទាប់នេះ។ ក្រោយពីកិច្ចប្រជុំនេះមក អង្គជំនុំជម្រះបានចេញនូវផែនការការងារលម្អិត ហើយអញ្ជើញភាគីឲ្យដាក់សារណាស្តីពីបទចោទដែលនឹងត្រូវបញ្ចូលទៅក្នុងសំណុំរឿង០០២/០២ ។[10] សវនាការតទល់គ្នាបានធ្វើឡើងនៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០១៤។ ក្នុងពេលសវនាការនេះ ភាគីបានធ្វើអំណះអំណាងផ្ទាល់មាត់ពាក់ព័ន្ធនឹងសារណារបស់ខ្លួនអំពីវិសាលភាពនៃបទចោទ ក៏ដូចជាជំហររបស់ខ្លួនទៅលើសារណាបន្ថែមរបស់មេធាវីការពារក្តីមួយ (ខៀវ សំផន) ទាក់ទិននឹងអត្ថិភាពនៃឧបសគ្គតាមផ្លូវច្បាប់ចំពោះការចាប់ផ្តើមសវនាការលើភស្តុតាងក្នុងសំណុំរឿង ០០២/០២ រហូតដល់មានសាលក្រមស្ថាពរក្នុងសំណុំរឿង០០២/០១។ អង្គជំនុំជម្រះសាលាដំបូងគ្រោងនឹងចេញសេចក្តីសម្រេចលើបញ្ហាទាំងពីរនេះ នៅខែមេសា ឆ្នាំ២០១៤។

23. នៅក្នុងសេចក្តីសន្និដ្ឋានផ្លូវការទៅកាន់អង្គជំនុំជម្រះសាលាដំបូង អំពីវិសាលភាពនៃសំណុំរឿង ០០២/០២ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យដាក់បញ្ចូលបទចោទនានាទាក់ទងនឹង ការប្រព្រឹត្តិលើជនជាតិចាម និងវៀតណាម មន្ទីរសន្តិសុខចំនួនបួន សហករណ៍មួយ និងការដ្ឋានពីរ។ ពួកគេក៏បានស្នើសុំដាក់បញ្ចូលបទចោទទាក់ទងនឹងការប្រព្រឹត្តិលើពុទ្ធសាសនិក នឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅសហករណ៍មួយ និងមន្ទីរសន្តិសុខមួយ។ សហព្រះរាជអាជ្ញាបានប៉ាន់ប្រមាណយ៉ាងច្បាស់ថាវាអាចទៅរួចក្នុងការបញ្ចប់សវនាការលើភស្តុតាង សម្រាប់សាក្សីដែលស្នើឡើងរបស់សហព្រះរាជអាជ្ញា នៅក្នុង ១០០ថ្ងៃសវនាការ ខណៈដែលទទួលស្គាល់ថា ថ្ងៃសវនាការបន្ថែមទៀតចាំបាច់ត្រូវមានដើម្បីស្តាប់សក្ខីកម្មសាក្សីបន្ថែម ដែលស្នើឡើងដោយភាគីនានា។ បន្ថែមលើទីតាំងដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំឱ្យបញ្ចូលការដ្ឋានមួយបន្ថែមទៀត និងមន្ទីរសន្តិសុខពីរបន្ថែមទៀត។ ពួកគេក៏ស្នើឱ្យបញ្ចូលបទចោទទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីបី ដែលទាក់ទងទៅនឹងការបោសសម្អាតនៅក្នុងភូមិភាគបូព៌ា ហើយពួកគេស្នើសុំឱ្យបញ្ចូលបទចោទទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នឹង ការប្រព្រឹត្តិលើពុទ្ធសាសនិកផ្តែកលើមូលដ្ឋានទូទាំងប្រទេស។ ក្រុមមេធាវីការពារក្តីមួយក្រុម (ខៀវ សំផន) បានសន្និដ្ឋានថា ដីកាដំណោះស្រាយដែលនៅសេសសល់ទាំងអស់ គប្បីដាក់បញ្ចូលក្នុងសំណុំរឿង ០០២/០២។ ក្រុមមេធាវីការពារក្តីទីពីរ (នួន ជា) បានតវ៉ាថា ដោយមិនគិតពីទីតាំងឧក្រិដ្ឋកម្មដែលបានបញ្ចូលក្នុងសំណុំរឿង ០០២/០២ ពួកគេគួរតែអាចបង្ហាញភស្តុតាងណាមួយពីសំណុំរឿង ០០២ ដែលពាក់ព័ន្ធទៅនឹងការការពារជនជាប់ចោទ។ ប្រសិនបើអង្គជំនុំជម្រះសម្រេចកំហិតវិសាលភាពនៃការជំនុំជម្រះមកត្រឹមទីតាំង និងបទចោទជាក់លាក់នោះ មេធាវីការពារក្តី នួន ជា ស្នើសុំឱ្យបញ្ចូលការដ្ឋានមួយបន្ថែមទៀត និងមន្ទីរសន្តិសុខមួយបន្ថែមទៀត ក៏ដូចជាការចោទប្រកាន់ពីគោលនយោបាយបោសសម្អាតផ្ទៃក្នុង និងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីបី។ ជាងនេះទៀត ក្រុមមេធាវីការពារក្តី នួន ជា មិនជំទាស់ទៅនឹងទីតាំងឧក្រិដ្ឋកម្ម និងបទចោទប្រកាន់បន្ថែម ដែលបានស្នើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

[9] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗជំទាស់នឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ (www.eccc.gov.kh/sites/default/files/documents/courtdoc/2013-07-23%2016:57/E284_4_7_EN.PDF)។

[10] ផែនការការងាររបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់សំណុំរឿង០០២/០២ (www.eccc.gov.kh/sites/default/files/documents/courtdoc/2014-01-02%2010:19/E301_5_EN.PDF)។

24. ចំនួនថ្ងៃសវនាការដែលត្រូវការដើម្បីបញ្ចប់ការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ អាចនឹងត្រូវបានព្យាករណ៍តែនៅពេលដែល (i) សេចក្តីសម្រេចលើវិសាលភាពរបស់វាត្រូវបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង និង (ii) ចំនួនសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលត្រូវកោះហៅមកផ្តល់សក្ខីកម្ម ត្រូវបានកំណត់ច្បាស់លាស់ដោយអង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីសាវណារបស់ភាគី ។ ហេតុដូច្នេះ ការព្យាករណ៍បច្ចុប្បន្នអំពីតារាងពេលវេលានៃសំណុំរឿង ០០២/០២ គឺផ្អែកលើការសន្មតថា ការជំនុំជម្រះទីពីរនឹងមានភាពស្មុកស្មាញ និងប្រើពេលវេលាច្រើនដូចគ្នានឹងការជំនុំជម្រះលើកទីមួយដែរ ប៉ុន្តែអាចមានការប្រែប្រួលខ្លាំង នៅពេលដែលកត្តាទាំងពីរនេះត្រូវបានកំណត់។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបន្ថែមទៀតរួចហើយថា “ភស្តុតាងដែលបានដាក់រួចហើយនៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ត្រូវប្រើជាមូលដ្ឋានមួយសម្រាប់សំណុំរឿង ០០២/០២” ដោយមិនចាំបាច់ធ្វើការពិនិត្យម្តងទៀតលើនីតិវិធីផ្លូវការនៃការទទួលយក ក្នុងអំឡុងពេលការជំនុំជម្រះនាពេលខាងមុខនោះទេ[11]។ វិធានការនេះនឹងមានផលវិជ្ជមានលើពេលវេលាដែលត្រូវការដើម្បីបញ្ចប់ការជំនុំជម្រះ។

25. រយៈពេលនៃការជំនុំជម្រះដែលស្មានទុកក៏ នឹងត្រូវប៉ះពាល់ដោយសារការសម្រេចណាមួយរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងតម្រូវការចាំបាច់ ក្នុងការកាត់បន្ថយចំនួនថ្ងៃសវនាការក្នុងមួយសប្តាហ៍ និងរយៈពេលនៃថ្ងៃមានសវនាការ ដោយសារស្ថានភាពសុខភាពរបស់ជនជាប់ចោទ។ ក្រុមមេធាវីការពារក្តីទាំងពីរក្រុមបានដាក់សារណាជាផ្លូវការរួចរាល់ហើយ ដែលនាំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់អ្នកជំនាញវិជ្ជសាស្ត្រពិនិត្យសម្បទារបស់ជនជាប់ចោទនៅក្នុងអំឡុងសប្តាហ៍ចុងក្រោយនៃខែមីនា ឆ្នាំ២០១៤។ ក្នុងករណីដែលភាគីស្នើសុំឱ្យមានសវនាការលើសម្បទា នោះអង្គជំនុំជម្រះសាលាដំបូងនឹងបើកសវនាការបែបនេះនៅក្នុងសប្តាហ៍ជាមួយគ្នានោះ។

26. ដោយពិចារណាលើកត្តាទាំងនេះ ការគ្រោងទុកល្អបំផុតដែលអាចផ្តល់ជូននាពេលបច្ចុប្បន្នសម្រាប់ការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ នោះគឺ អង្គជំនុំជម្រះសាលាដំបូងនឹង (i) ធ្វើការប្រជុំរៀបចំសវនាការយ៉ាងហោចណាស់ចំនួនមួយបន្ថែមទៀត ក្នុងពេលណាមួយសមស្រប ក្នុងឆ្នាំ២០១៤ អាស្រ័យលើស្ថានភាពនីតិវិធីរបស់រឿងក្តី (ii) ប្រសិនបើចាំបាច់ សវនាការលើសម្បទាក្នុងការចូលរួមការជំនុំជម្រះរបស់ជនជាប់ចោទ នៅចុងខែមីនា ឆ្នាំ២០១៤ (iii) សេចក្តីសម្រេចលើវិសាលភាពនៃសំណុំរឿង ០០២/០២ ក្នុងខែមេសា និង (iv) សវនាការបឋមត្រឹមត្រីមាសទីបី ឆ្នាំ២០១៤។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងកំពុងធ្វើការឆ្ពោះទៅរកការចាប់ផ្តើមសវនាការលើអង្គសេចក្តី នៅត្រីមាសចុងក្រោយ ឆ្នាំ២០១៤។

27. បន្ទាប់ពីធ្វើសេចក្តីសម្រេចលើវិសាលភាពនៃសំណុំរឿង០០២/០២ ក្នុងខែមេសា ឆ្នាំ២០១៤ រួចមកភាគីនានានឹងត្រូវបានផ្តល់ឱកាសឲ្យដាក់សារណាជូនអង្គជំនុំជម្រះសាលាដំបូងអំពីអង្គហេតុ និង/ឬបទចោទប្រកាន់នានា ដែលមិនបានបញ្ចូលនៅក្នុងសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២។ ក្របខ័ណ្ឌគតិយុត្តដែលគ្រប់ដណ្តប់នីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ មិនមានចែងច្បាស់លាស់អំពីការទម្លាក់ការចោទប្រកាន់ ឬអង្គហេតុដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ។ យ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា “ការដកចេញនូវបទចោទប្រកាន់ អាចត្រូវបានអនុញ្ញាតផ្អែកតាមយុត្តិសាស្ត្រអន្តរជាតិ “ដរាបណាបញ្ហាទាំងនេះត្រូវបានដោះស្រាយប្រកបដោយតម្លាភាព ដោយធ្វើការពិចារណាទៅលើផលប្រយោជន៍យុត្តិធម៌ និងសិទ្ធិដែលពាក់ព័ន្ធក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដោយមានការព្រមព្រៀងពីសហព្រះរាជអាជ្ញា

[11] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា “ការបំភ្លឺទាក់ទងនឹងការប្រើភស្តុតាង និងនីតិវិធី សម្រាប់កោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ពីសំណុំរឿង ០០២/០១ ក្នុងសំណុំរឿង ០០២/០២” (www.eccc.gov.kh/sites/default/files/documents/courtdoc/2014-02-07%2016:14/E302_5_EN.PDF)។

និងអង្គជំនុំជម្រះសាលាដំបូង"[12]។ អង្គជំនុំជម្រះសាលាដំបូងត្រូវការវាយតម្លៃវិសាលភាពនៃអំណាចទាំងនេះឲ្យបានច្បាស់ ដែលមានអានុភាពអនុវត្តចំពោះរឿងក្តីនេះ។

## ឃ. សំណុំរឿង០០៣ និង សំណុំរឿង០០៤

28. លុះត្រាតែមានសេចក្តីសម្រេចថាតើ សំណុំរឿង០០៣ និង/ឬ០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ ទើបអាចធ្វើការស្មានទុកបានទៅលើរយៈពេលសម្រាប់បញ្ចប់ការជំនុំជម្រះក្តីទាំងនេះ។ ការវាយតម្លៃលើពេលវេលាដែលតម្រូវ អាចផ្អែកទៅលើចំនួនចុងចោទ ក៏ដូចជាចំនួន និងភាពស្មុគស្មាញនៃអង្គហេតុ និងអង្គច្បាប់នៃបទចោទ និងទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

## V. ផែនការបញ្ចប់បណ្តឹងសាទុក្ខ

29. ដើម្បីធ្វើការប៉ាន់ស្មានអំពីរយៈពេលសម្រាប់ដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ត្រូវតែញែកឲ្យបានច្បាស់អំពីដំណាក់កាលបណ្តឹងសាទុក្ខ ដូចតទៅ៖ ដំណាក់កាលទីមួយ គឺត្រូវការពេលវេលាសម្រាប់ដាក់សារណារបស់ភាគីទាំងអស់។ អនុលោមតាមវិធានផ្ទៃក្នុង ភាគីត្រូវដាក់សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខក្នុងរយៈពេល ៣០ថ្ងៃ ក្រោយពីការប្រកាសសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ ក្នុងករណីដែលមានបណ្តឹងសាទុក្ខ ដោយភាគីណាមួយ ភាគីដទៃទៀតមានរយៈពេលបន្ថែម ១៥ថ្ងៃ ទៀត ដើម្បីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ។ ម្ចាស់បណ្តឹងសាទុក្ខត្រូវដាក់ជូនសារណាបណ្តឹងសាទុក្ខក្នុងរយៈពេល ៦០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងពីការប្តឹងសាទុក្ខ។ ភាគីនឹងមានរយៈពេល ១០ថ្ងៃ ក្នុងការដាក់ចម្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ភាគីដទៃទៀត។ ប៉ុន្តែកាលពីពេលកន្លងទៅ អង្គជំនុំជម្រះបានផ្តល់ជូនរយៈពេលបន្ថែមសមរម្យសម្រាប់ដាក់ចម្លើយតប។ ក្នុងអំឡុងពេលនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងស្រាវជ្រាវទៅលើបញ្ហាច្បាប់ និងអង្គហេតុដែលពាក់ព័ន្ធ ដើម្បីរៀបចំខ្លួនពេញលេញសម្រាប់សវនាការលើបណ្តឹងសាទុក្ខដែលជាដំណាក់កាលទីពីរ។ សវនាការលើបណ្តឹងសាទុក្ខអាចត្រូវបានបង្គាប់ នៅពេលណាភាគីបានដាក់សារណាទាំងអស់របស់ខ្លួនរួចហើយ។ ដំណាក់កាលទីបី គឺ ការពិភាក្សាសម្រេចក្រោយពេលសវនាការនោះ និងការរៀបចំចេញសាលដីកាលើបណ្តឹងសាទុក្ខ។

30. ការព្យាករណ៍ត្រឹមត្រូវមិនអាចធ្វើទៅបានទេក្នុងករណីគ្មានសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង និងរាល់ការចង្អុលបង្ហាញណាមួយទាក់ទិនថាតើភាគីមួយចំនួន ឬទាំងអស់ មានបំណងប្តឹងសាទុក្ខ ហើយបើមានបំណងមែន តើដល់កម្រិតណានោះ។ ហេតុដូច្នេះការព្យាករណ៍បច្ចុប្បន្ននេះគឺផ្អែកលើសេណារីយោនៃរឿងក្តីតាមសម្មតិកម្ម ដែលក្នុងនោះសំអាងហេតុទាំងអស់នៅក្នុងសាលក្រមសំណុំរឿង០០២/០១ ត្រូវបានប្តឹងសាទុក្ខដោយភាគីមួយ ឬច្រើន ក្នុងនោះរួមមានបណ្តឹងសាទុក្ខលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមិនអាចលើកឡើងនៅកំឡុងពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ក៏ដូចជាការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលត្រូវបានចោទឡើង។ ដោយពិចារណាទៅលើកាលកំណត់កាលបរិច្ឆេទដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក. និងយុត្តិសាស្ត្រដែលទាក់ទិនសម្រាប់រឿងក្តីដែលមានទំហំ និងភាពស្មុគស្មាញប្រហាក់ប្រហែលគ្នា អាចនាំឲ្យមានការប៉ាន់ស្មានដ៏ត្រឹមត្រូវមួយនាពេលនេះគឺថា ក្នុងករណីដែលសាលក្រមក្នុងសំណុំរឿង០០២/០១ ត្រូវបានបណ្តឹងសាទុក្ខតាមវិធីនេះ វានឹងត្រូវការពេល១៨ខែទើបចប់ពេញលេញ។ ៨ ទៅ ៩ ខែដំបូង នឹងទាក់ទិននឹងការរៀបចំដាក់សារណារបស់ភាគីទាំងអស់ បន្ទាប់មកគឺការរៀបចំសវនាការ

---

[12] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ឯកសារ E284/4/8 ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ កថាខណ្ឌ ៦២ (www.eccc.gov.kh/sites/default/files/documents/courtdoc/2014-01-03%2012:17/E284_4_8_EN-2.PDF)។

លើបណ្តឹងសាទុក្ខណាមួយនោះ។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវការរយៈពេល៩ ទៅ១០ ខែទៀត ដើម្បីបញ្ចប់នូវការពិភាក្សាសម្រេច និងរៀបចំចេញសាលដីការបស់ខ្លួនក្នុងសំណុំរឿង ០០២/០១។

31. សម្រាប់សំណុំរឿង០០២/០២ ដោយផ្អែកលើការព្យាករណ៍បច្ចុប្បន្នរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាការជំនុំជម្រះដំណាក់កាលទីពីរទំនងជានឹងមានលក្ខណៈស្មុគស្មាញ និងត្រូវការពេលវេលាច្រើនដូចការជំនុំជម្រះដំណាក់កាលទីមួយនោះ អង្គជំនុំជម្រះតុលាការកំពូលក៏ព្យាករណ៍ស្រដៀងគ្នានេះដែរនៅពេលនេះថា បណ្តឹងសាទុក្ខទីពីរនឹងមានលក្ខណៈស្មុគស្មាញនិងត្រូវការពេលវេលាច្រើនដូចគ្នានឹងបណ្តឹងសាទុក្ខទី១ដែរ។

32. ទោះជាយ៉ាងណា គួរកត់សម្គាល់ថា កត្តាមួយចំនួន ដូចជាសំណើសុំពន្យារពេលក្នុងការដាក់សារណាឬញត្តិ ដើម្បីស្នើដាក់ជូនភស្តុតាងបន្ថែម អាចប៉ះពាល់ដល់រយៈពេលនៃដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ហើយនឹងត្រូវការគិតបញ្ចូលទៅក្នុងការរៀបចំផែនការ ក្រោយពេលមានការដាក់បណ្តឹងសាទុក្ខផងដែរ។ ជាងនេះទៅទៀត បណ្តឹងសាទុក្ខភ្លាមៗដែលអាចកើតមានចេញពីសំណុំរឿង០០២/០២ ដែលត្រូវតែសម្រេចក្នុងរយៈពេលបីខែជាកំណត់ អាចធ្វើឲ្យមានតម្រូវការធនធាន របស់អង្គជំនុំជម្រះតុលាការកំពូលកាន់តែច្រើនឡើង។

## VI. សេចក្តីសន្និដ្ឋាន

33. សម្រាប់ឆ្នាំ២០១៤ រំពឹងថានឹងសម្រេចបាននូវគ្រោងការចំនួនប្រាំពីរ៖ (i) ការចេញសាលក្រមលើសំណុំរឿង០០២/០១ (ii) ពេលវេលាកំណត់សម្រាប់ដាក់បណ្តឹងសាទុក្ខ ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ (iii) ការចេញសេចក្តីសម្រេចលើវិសាលភាពនៃ សំណុំរឿង០០២/០២ (iv) ការបើកសវនាការបឋមក្នុងសំណុំរឿង០០២/០២ (v) ការចាប់ផ្តើមសវនាការលើអង្គសេចក្តី/ភស្តុតាងក្នុងសំណុំរឿង ០០២/០២ (vi) សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ ក្នុងសំណុំរឿង០០៣ នឹង ០០៤ និង (vii) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ និង សំណុំរឿង ០០៤ ជាមួយនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ថាតើត្រូវបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធីតែម្តង។

34. សម្រាប់ឆ្នាំ២០១៥ កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០២ នឹងបន្តពេញរយៈពេលមួយឆ្នាំ ហើយមានការរំពឹងថានឹងសម្រេចបាននូវគ្រោងការថ្មីចំនួនមួយ ពោលគឺ (i) ការសម្រេចលើបណ្តឹងឧទ្ធរណ៍ណាមួយ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿងទាំងនេះ ជាមួយនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះថាតើត្រូវបញ្ជូនសំណុំរឿងទាំងនេះទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធីតុលាការ។ ក្នុងករណីដែលសំណុំរឿងណាមួយ ឬសំណុំរឿងទាំងពីរ ត្រូវបានបញ្ជូនទៅជំនុំជម្រះ ទាំងមូល ឬដោយផ្អែក ការព្យាករណ៍ទុកនូវតារាងកំណត់ពេលវេលាក្នុងសំណុំរឿងទាំងនេះគឺអាចយកមកវាយតម្លៃបាន។

35. សម្រាប់ឆ្នាំ២០១៦ មានការរំពឹងថានឹងសម្រេចបាននូវគ្រោងការចំនួនបី គឺ៖ (i) ការចេញសាលដីកាលើបណ្តឹងសាទុក្ខលើសំណុំរឿង០០២/០១ (ii) ការបញ្ចប់សវនាការលើអង្គសេចក្តី/ភស្តុតាងក្នុងសំណុំរឿង០០២/០២ (iii) ការបញ្ចប់សេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលក្នុងសំណុំរឿង ០០២/០២។

36. សម្រាប់ឆ្នាំ២០១៧ មានការរំពឹងថានឹងសម្រេចបាននូវគ្រោងការចំនួនពីរ គឺ៖ (i) ការចេញសាលក្រមលើសំណុំរឿង០០២/០២ និង (ii) ពេលវេលាកំណត់សម្រាប់ដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង០០២/០២។

37. ក្នុងអំឡុងឆ្នាំ២០១៨ អង្គជំនុំជម្រះតុលាការកំពូលនឹងជាប់រវល់ធ្វើសវនាការបណ្តឹងសាទុក្ខ និងការពិភាក្សាសម្រេច ក្នុងករណីដែលមានបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។

38. សម្រាប់ឆ្នាំ២០១៩ មានការរំពឹងថានឹងសម្រេចបាននូវគ្រោងការចំនួនមួយ គឺ ៖ (i) ការចេញសាលដីកាលើសំណុំរឿង០០២/០២។

39. ការស្មានទុកនូវគ្រោងការនានាដែលរៀបរាប់ខាងលើនេះ មានសង្ខេបជូនក្នុងតារាងដែលភ្ជាប់ជូនជាមួយនឹងផែនការនេះស្រាប់។

# តារាងកំណត់ពេលវេលាតាមការគ្រោងទុក ដែលរួមមានព្រឹត្តិការណ៍សំខាន់ៗ

| សំណុំរឿង | ២០១៤ | | | | ២០១៥ | | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ |
| សំណុំរឿង០០២/០១ | ដំណាក់កាលជំនុំជម្រះ | (i) | (ii) | | | បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម | | | (iii) | | | | | | | | | | | | | | | |

(i) សាលក្រម សំណុំរឿង ០០២/០១
(ii) កាលបរិច្ឆេទកំណត់សម្រាប់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម សំណុំរឿង ០០២/០១
(iii) សាលដីកា សំណុំរឿង ០០២/០១

| | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សំណុំរឿង០០២/០២ | ការងារត្រៀម | (iv) | (v) | (vi) | | | | | ដំណាក់កាលជំនុំជម្រះ | (vii) | | (viii) | | | (ix) | (x) | | | បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម | | | (xi) | | |

(iv) សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើវិសាលភាពនៃសំណុំរឿង ០០២/០២
(v) សវនាការបឋម សំណុំរឿង ០០២/០២
(vi) ការចាប់ផ្ដើមសវនាការលើអង្គសេចក្ដី សំណុំរឿង ០០២/០២
(vii) ការបញ្ចប់សវនាការលើអង្គសេចក្ដី សំណុំរឿង ០០២/០២
(viii) សេចក្ដីសន្និដ្ឋានបិទការពិភាក្សាដេញដោល សំណុំរឿង ០០២/០២
(ix) សាលក្រម សំណុំរឿង ០០២/០២
(x) កាលបរិច្ឆេទកំណត់សម្រាប់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម សំណុំរឿង ០០២/០២
(xi) សាលដីកា សំណុំរឿង ០០២/០២

| | | | | | | |
|---|---|---|---|---|---|---|
| សំណុំរឿង ០០៣ | | កិច្ចស៊ើបសួរតាមផ្លូវតុលាការ (xii) | | (xiii) | បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ | (xiv) |
| សំណុំរឿង ០០៤ | | កិច្ចស៊ើបសួរតាមផ្លូវតុលាការ (xii) | | (xiii) | បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ | (xiv) |

(xii) ការជូនដំណឹងអំពីការបញ្ចប់ការស៊ើបអង្កេត
(xiii) ដីកាដំណោះស្រាយ ក.ស.ច.ស.
(xiv) ដីកាដំណោះស្រាយ អ.ប.ជ.